ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តបន្ទាយមានជ័យ
ស្រុកមង្គលបូរី
រដ្ឋបាលឃុំសំបួរ

លេខ.១២/២២......./២២ ដ.ក

ដីកា
ស្តីពី
ការលើកទឹកចិត្តយុវជនចូលរួមក្នុងកិច្ចការសង្គម

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- យោងអនុក្រឹត្យលេខ ២២ អនុក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលស្តីពីការធ្វើវិមជ្ឈការ អំណាច តួនាទី និងភារៈកិច្ចទៅអោយក្រុមប្រឹក្សាឃុំ ។
- យោងកិច្ចប្រជុំកាលពីថ្ងៃទី..៣១..ខែ.តុលា...ឆ្នាំ២០២២ របស់ក្រុមប្រឹក្សាឃុំសំបួរនិងយោងតាមការពិភាក្សាសម្រេចលើដីកា ស្តីពីការលើកទឹកចិត្តដល់យុវជនក្នុងការចូលរួម ក្នុងកិច្ចការសង្គមក្នុងឃុំសំបួរ។
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋបាលឃុំសំបួរដោយយល់ឃើញថា បញ្ហាកង្វះការចូលរួមរបស់យុវជនក្នុងកិច្ចការសង្គម ជាពិសេសការចូលរួមនៅក្នុងការធ្វើ ផែនការអភិវឌ្ឍន៍ឃុំ អាចមិនឆ្លើយតបទៅ នឹង តម្រូវការរបស់យុវជននៅក្នុងសហគមន៍នៃឃុំសំបួរ។

ដោយមើលឃើញពីការប្រឈមរបស់យុវជនដែលពុំសូវមានឱកាសក្នុងការចូលរួមក្នុងកិច្ចការសង្គម និងដើម្បីលើកទឹកចិត្តដល់យុវជនឱ្យចូលយ៉ាងសកម្ម ក្រុមប្រឹក្សាឃុំសំបួរ

សម្រេច

ប្រការ១._ ដីកានេះមានគោលបំណង លើកកម្ពស់សិទ្ធិ និងការចូលរួមរបស់យុវជនក្នុងកិច្ចការសង្គម និងផ្តល់ឱកាសដល់យុវជនខ្មែរទាំងពីរភេទបានចូលរួមយ៉ាងសកម្មនៅក្នុងការផ្តល់យោបល់ និងលើកឡើងនូវកង្វល់នានាដែលពាក់ព័ន្ធទៅនឹងតម្រូវការរបស់យុវជនតាមគោលគំនិត និងក្តីស្រមៃរបស់ខ្លួន។

ប្រការ២._ ដីកានេះមានវិសាលភាពអនុវត្តតែនៅក្នុងដែនដី នៃឃុំសំបួរ។

ប្រការ៣._ រដ្ឋបាលឃុំផ្តល់ឱកាស និងលើកទឹកចិត្តក្រុមយុវជនចូលរួម កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ។

ប្រការ៤._ រដ្ឋបាលសង្កាត់ផ្តល់ឱកាស និងលើកទឹកចិត្តឱ្យក្រុមយុវជនចូលរួមនៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសំបួរ ។

ប្រការ៥._ រដ្ឋបាលឃុំនឹងស្វែងរកកិច្ចសហការ ទូលំទូលាយជាមួយអ្នកពាក់ព័ន្ធ រួមទាំងអង្គការ ជាពិសេសយុវជនដែលទទួលបានជោគជ័យ ក្នុងការចូលរួមក្នុងកិច្ចការសង្គម ឱ្យចែករំលែកបទពិសោធន៍ និងផ្តល់ការបណ្តុះបណ្តាលដល់យុវជនពីសិទ្ធិមនុស្ស ប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងសារៈសំខាននៃការចូលរួមរបស់យុវជននៅក្នុងឃុំ ។

ប្រការ៦._ រដ្ឋបាលឃុំ នឹង រៀបចំឱ្យមានការដាក់បង្ហាញ អំពីតារាងតម្លៃសេវារដ្ឋបាល ឱ្យបានទូលំទូលាយនៅតាមភូមិ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹង ពីតម្លៃសេវារដ្ឋបាលនៃការផ្តល់សេវារបស់របស់ឃុំ ប្រកបដោយតម្លាភាព។

ប្រការ៧._រដ្ឋបាលឃុំ នឹង ចែករំលែកព័ត៌មានពាក់ព័ន្ធពីការចូលរួមរបស់យុវជន ក្នុងកិច្ចការសង្គម និងឱកាសសម្រាប់ការចូលរួមរបស់យុវជន ជាមួយក្រុមប្រឹក្សាឃុំ ដល់ប្រជាពលរដ្ឋក្នុងឃុំ ជាពិសេសសយុវជន តាមរយៈការបិទផ្សាយនៅក្តារព័ត៌មាននៅតាមភូមិ និងនៅសាលាឃុំ និងទំព័រហ្វេសបុកផ្លូវការរបស់រដ្ឋបាលឃុំ។

ប្រការ៨._រដ្ឋបាលឃុំ នឹងបង្កលក្ខណៈងាយស្រួលដល់បណ្តាញ/ក្រុមយុវជនបានជួបជុំពិភាក្សាគ្នា និងផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស ប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងតួនាទីរបស់យុវជនក្នុងការចូលរួមក្នុងកិច្ចការសង្គមដល់ប្រជាពលរដ្ឋ ជាពិសេសយុវជននៅក្នុងសហគមន៍ឱ្យបានយល់ដឹងយ៉ាងទូលំទូលាយ។

ប្រការ៩._ ក្រុមប្រឹក្សាឃុំសំបួរ នឹងជួយសម្រួលរាល់ឯកសារដែលទាក់ទងទៅនឹងតម្រូវការរបស់យុវជនជាមួយនឹងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

ប្រការ១០._ ដីកានេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ[illegible]ខែ..ភទ្ទ..ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

បន្ទាយមានជ័យថ្ងៃទី..៣១..ខែ..តុលា..ឆ្នាំ២០២២

ឈប់ សុភ័ណ្ឌ

ចំលងជូន

- រដ្ឋបាលស្រុកមង្គលបូរី
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមស្រុកមង្គលបូរី
  "ដើម្បីគោរពជូនជ្រាប"
- មេភូមិគ្រប់ភូមិ
  "ដើម្បីសហការអនុវត្តន៍"
- ឯកសារ-កាលប្បវត្តិ